# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ ៖ ខ្មែរមានការព្រួយបារម្ភអំពីការបាត់បង់ទឹកដី ដោយវៀតណាមជាងដោយប្រទេសថៃ ។

**Website: www.hoksavann.org**

ថ្ងៃទី១១ សីហា ២០១០



តាមប្រវត្តិសាស្ត្រ ប្រទេសវៀតណាមនិងប្រទេសថៃតែងតែឈ្លានពានរំលោភយកទឹកដីប្រទេសកម្ពុជាជានិច្ច ។ ដោយការឈ្លានពាននេះ ខ្មែរបានបាត់បង់ទឹកដីអស់ជាច្រើន ដូចជាកម្ពុជាក្រោមក្នុងប្រទេសវៀតណាម ខេត្តសុរិន ខេត្តបុរីរាមក្នុងប្រទេសថៃជាដើម ។ បច្ចាមិត្តដែលអាចចូលមកឈ្លានពានបាន មួយភាគកើតឡើងពីខ្មែរខ្លួនឯងមានទំនាស់ផ្ទៃក្នុង មួយក្រុមទៅពឹងយួន មួយក្រុមទៅពឹងថៃ ឲ្យមកជួយកំទេចខ្មែរគ្នាឯង ។ រហូតមកទល់ពេលនេះ ប្រទេសទាំងពីរនេះនៅតែមានមហិច្ឆិតាចង់បានទឹកដីខ្មែរដដែល ។ សព្វថ្ងៃនេះ ប្រជាពលរដ្ឋខ្មែរទូទៅមានការព្រួយបារម្ភអំពីការបាត់បង់ទឹកដីដោយប្រទេសវៀតណាមជាងប្រទេសថៃ ។

ព្រួយបារម្ភពីប្រទេសវៀតណាមខ្លាំងជាង ព្រោះមានភស្តុតាងជាច្រើនយ៉ាងរឹងមាំ ដូចជាសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ ដែលធ្វើឲ្យសន្ធិសញ្ញាអំឡុងឆ្នាំ១៩៨០ ដែលមិនស្របច្បាប់ធ្វើឲ្យស្របច្បាប់ ។ បោះបង្គោលចូលមកដីស្រែរបស់កសិករខ្មែរជាច្រើនគីឡូម៉ែត្រ ដូចជាករណីដីស្រែរបស់កសិករខ្មែរនៅខេត្តស្វាយរៀងជាដើម ។ គេសង្កេតឃើញថា រាជរដ្ឋាភិបាលខ្មែរសព្វថ្ងៃនេះហាក់ដូចជានៅក្រោមអំណាចវៀតណាម ព្រោះមានភស្តុតាង បើវៀតណាមមានបំណងយ៉ាងណា រាជរដ្ឋាភិបាលខ្មែរតែងតែបំពេញតាមបំណងនោះ ដូចជាសន្ធិសញ្ញាបំពេញបន្ថែម, បញ្ហាផ្សឹកព្រះសង្ឃទីម-សាខន, បញ្ហាកាត់ទោសអ្នកដកតម្រុយបង្គោលព្រំដែននៅខេត្តស្វាយរៀង, ការមិនជួយសំរួលខ្មែរកម្ពុជាក្រោម ដែលរត់ចូលមកដល់ប្រទេសកម្ពុជា ដោយការគាបសង្កត់ពីវៀតណាម ផ្ទុយទៅវិញរាជរដ្ឋាភិបាលខ្មែរបែរជាជួយសំរួលដល់សមាគមវៀតណាម២៤ខេត្តនៃប្រទេសកម្ពុជា ឲ្យបំពេញសកម្មភាពដោយសេរី និងយ៉ាងសុខស្រួលទៅវិញ ។ គេបានបារម្ភថា ការផ្តល់សម្បទានដីរាប់សែនហិកតាដល់វៀតណាមចំនួន៩៩ឆ្នាំ ជាឱកាសល្អដែលអាចឲ្យវៀតណាមចូលមករស់នៅក្នុងប្រទេសកម្ពុជាជាអចិន្ត្រៃយ៍ ទោះបីវៀតណាមបង្កើតកងទ័ពនៅក្នុងដីសម្បទានដ៏ច្រើនហិកតានោះ ក៏ពុំអាចអ្នកណាដឹង ឬចាប់អារម្មណ៍ឡើយ ដោយយកការដាំកៅស៊ូជារនាំងបាំងមុខ ។ រាជរដ្ឋាភិបាលខ្មែរហាក់ដូចជាលាក់លៀមមិនបានប្រកាសឲ្យច្បាស់ថា តើវៀតណាមដែលរស់នៅប្រទេសកម្ពុជាសព្វថ្ងៃនេះ ទាំងស្របច្បាប់និងមិនស្របច្បាប់មានចំនួនប៉ុន្មាននាក់ ។ អង្គការក្រៅរដ្ឋាភិបាលតែងប្រកាសជាញឹកញាប់ថា វៀតណាមខុសច្បាប់ដែលមករស់នៅប្រទេសកម្ពុជាមានចំនួនជាច្រើនលាននាក់ គឺពីរលានទៅបួនលាននាក់ ។ អ្នកខ្លះនិយាយដោយសើចលេងផងថា វៀតណាមមិនបាច់រំកិលព្រំដែនទេ តែវៀតណាមចូលមកនៅប្រទេសកម្ពុជាតែម្តង ។ អ្នកនិយាយសើចលេងបន្តថា បន្តិចទៀតខ្មែរនឹងទៅជាជនជាតិភាគតិចនៅក្នុងប្រទេសកំណើតរបស់ខ្លួន ។

មិនសូវមានការព្រួយបារម្ភមហិច្ឆិតារបស់ថៃក្នុងការបាត់បង់ទឹកដីខ្មែរតទៅទៀត ព្រោះខ្មែរមានច្បាប់ធានាជាច្រើនផ្អែកហើយ ។ អនុសញ្ញាឆ្នាំ១៩០៤និងឆ្នាំ១៩០៧ ព្រមទាំងផែនទីបានចុះហត្ថលេខាព្រមព្រៀងគ្នារវាងអាណានិគមនិយមបារាំងជាមួយនិងភាគីថៃ ។ តុលាការអន្តរជាតិក្រុងឡាអេ បានកាត់ឲ្យខ្មែរឈ្នះថៃក្នុងរឿងក្តីព្រះវិហារថ្ងៃ១៥មិថុនា១៩៦២ ។ ក្រោយពេលដែលនាយករដ្ឋមន្ត្រីថៃបានថ្លែងការណ៍កាលពីថ្ងៃ៧ សីហា ២០១០ថា ថៃនឹងលុបចោលនូវអនុស្សរណៈនៃការយោគយល់គ្នារវាងខ្មែរនិងថៃ ចុះថ្ងៃទី១៥ មិថុនា ២០០០ ហើយដើម្បីឈ្នះខ្មែរ ថៃនឹងប្រើមធ្យោបាយទូតនិងមធ្យោបាយយោធា ពេលនោះនាយករដ្ឋមន្ត្រីខ្មែរបានផ្ញើលិខិតពីរចុះថ្ងៃទី៨ សីហា ២០១០ ទៅប្រធានមហាសន្និបាតនៃអង្គការសហប្រជាជាតិ និងប្រធានក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ជំរាបជូនអង្គការទាំងពីរនេះ អំពីការគំរាមកំហែងរបស់ថៃក្នុងដំណោះស្រាយបញ្ហាប្រាសាទព្រះវិហារ ជាពិសេសទំហំដី៤.៦គីឡូម៉ែត្រក្រឡានៅក្បែរព្រះវិហារ ដែលថៃគូរផែនទីដោយខ្លួនឯងជាឯកតោភាគី ។ លិខិតនោះសង្កត់ធ្ងន់ ត្រង់ថៃបំណងប្រើកម្លាំងយោធាមកលើប្រទេសកម្ពុជា ។ ថៃបានឆ្លើយបដិសេធចំពោះពត៌មាននេះ ហើយថាថៃគ្មានបំណងប្រើកម្លាំងយោធាទេ តាមលិខិតដែលថៃផ្ញើបញ្ជាក់ទៅអ.ស.ប. ។

យើងយល់ថា ថៃមិនចង់ឲ្យច្បាប់អន្តរជាតិកាត់សេចក្តីទេ ពាក្យដែលថៃពោលថានឹងប្រើកម្លាំងយោធានោះ ជាពាក្យគំរាមកំហែងខ្មែររបៀបតថ្លៃ ថៃពិតជាត្រឡប់មកចរចាជាទ្វេភាគីវិញពុំខាន ។ ការចរចាជាទ្វេភាគីតាំងពីខែកក្កដា២០០៨ចំនួន២ឆ្នាំគ្មានបានផលអ្វីសោះ បើបន្តចរចាទៅមុខទៀត តើបានផលឬទេ ? ខ្មែរមានបង្អែកយ៉ាងមាំ គឺអនុសញ្ញាឆ្នាំ១៩០៤, ១៩០៧ រវាងបារាំង-សៀម និងតុលាការក្រុងឡាអេឆ្នាំ១៩៦២ ជាពិសេសកិច្ចព្រមព្រៀងអន្តរជាតិថ្ងៃ២៣ តុលា ១៩៩១នៅប៉ារីសស្តីពីសន្តិភាពប្រទេសកម្ពុជា ដែលធានាឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី ដែលថៃជាហត្ថលេខីមួយដែរ ។ គួរប្រើសន្ធិសីទនេះ ដើម្បីឲ្យមានការធានាជាអន្តរជាតិ កុំឲ្យថៃសើរើវិញបាន ។

❄ ❄

❄